USDA

USAID
ជំនួយពីពលរដ្ឋអាមេរិក

WFP
World Food Programme

SAVING LIVES
CHANGING LIVES

# បច្ចុប្បន្នភាពទីផ្សារ និងការតាមដានរដូវកាល

ខែមិថុនា ឆ្នាំ២០២៤

## ប្រទេសកម្ពុជា

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ



**វិភាគ និងធ្វើផែនទីភាពងាយរងគ្រោះ (VAM)**
ផ្នែកស្រាវជ្រាវ វាយតម្លៃ និងតាមដាន (RAM) កម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ
ឡុង យ៉ាវ yav.long@wfp.org, ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org,
ហួយ វណ្ណារ៉េត vannareth.huoy@wfp.org, Eltone Mabodo eltone.mabodo@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**តម្លៃស្បៀងអាហារសកល ក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០២៤ បង្ហាញនិន្នាការកើនឡើងបន្តិច** ដោយសារជម្លោះភូមិសាស្ត្រនយោបាយដែលកំពុងបន្ត ឥទ្ធិពលនៃបាតុភូតអែលនីញ៉ូលើពាណិជ្ជកម្ម និងកសិកម្មសកល និងការបិទខ្ទប់ការនាំចេញស្បៀងអាហាររបស់ប្រទេសជាអ្នកផលិតសំខាន់ៗ។

**ក្នុងខែមិថុនា ឆ្នាំ២០២៤ <u>សន្ទស្សន៍តម្លៃស្បៀងអាហារពិភពលោករបស់FAO</u> មិនមានការប្រែប្រួលនោះទេបើធៀបនឹងខែមុន (MoM)។** នេះដោយសារការកើនឡើងតម្លៃប្រេងឆា ស្ករ និងផលិតផលធ្វើពីទឹកដោះគោបានទូទាត់ជាមួយការថយចុះតម្លៃធញ្ញជាតិ ចំណែកតម្លៃសាច់មានស្ថេរភាព។ ប៉ុន្តែតម្លៃសន្ទស្សន៍នៅតែទាបជាងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ២,១%។ <u>សន្ទស្សន៍តម្លៃអង្ករសរុបរបស់ FAO</u> បានថយចុះ ០,៦% MoM ប៉ុន្តែ បានកើនឡើង ៨,២% YoY។

**តម្លៃអង្ករសកល ត្រូវបានព្យាករថានឹង<u>កើនឡើង ៦% ក្នុង ឆ្នាំ២០២៤</u>** បន្ទាប់ពីបានកើនឡើង ២៨% ក្នុងឆ្នាំ២០២៣។ ការកើនឡើងតម្លៃអង្ករ ដែលបង្កឡើងដោយតម្រូវការកើនឡើង និងការផ្គត់ផ្គង់ថយចុះ កំពុងបង្កើនក្តីបារម្ភ ពីសន្តិសុខស្បៀងពិភពលោក ដោយសារអង្ករជាអាហារចម្បង សម្រាប់មនុស្សជាង <u>៣ ពាន់លាននាក់</u>។

វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ ស្បៀងអាហារអន្តរជាតិ (IFPRI) បាន**ព្រមានថា <u>កុមារ ១,២៧ លាននាក់ អាចប្រឈមនឹងបញ្ហាកង្វះអាហារូបត្ថម្ភ</u>** ដោយសារតែវិបត្តិតម្លៃស្បៀងអាហារ ព្រោះមានការព្យាករថា តម្លៃស្បៀងអាហារកើនឡើង ៥% ក្នុងរយៈពេល៣ខែបន្ទាប់ អាចបង្កើនហានិភ័យនៃភាពស្គមស្គាំង ឬស្គមស្គាំងធ្ងន់ធ្ងរ។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀង នៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា** កម្មវិធីស្បៀងអាហារពិភពលោក (WFP) តាមដានតម្លៃស្បៀងអាហារសំខាន់ៗ និងដំណើរការរបស់ផ្សារចំនួន៥៨។ ចាប់តាំងពីខែមករា ឆ្នាំ២០២៤ ប្រធានផ្សារ និងអាជីវករចំនួនប្រហែល ៧៥០ នាក់ ត្រូវបានសម្ភាសន៍នៅសប្តាហ៍ទីបីនៃខែនីមួយៗ ដើម្បីវាយតម្លៃពីការផ្គត់ផ្គង់ និងតម្រូវការ (សូមមើល <u>វិធីសាស្ត្រ</u>)។ តម្លៃប្រេងសាំង និង ប្រេងម៉ាស៊ូត ក៏ត្រូវបានតាមដានផងដែរ។

## មាតិកា


១. កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ ២
២. ទិដ្ឋភាពទូទៅ និងរបកគំហើញសំខាន់ៗ ៣
៣. លទ្ធផល
ការដំណើរការរបស់ផ្សារ ៤
ការទៅផ្សារ៖ ទិន្នាការអតិថិជន ៥
ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦
ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ីតទា និងត្រកួន ៧
ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូកបីជាន់ និងប្រេងឆា ៨
ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ៩
ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១០
ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១១
៤. បរិបទ
ពាណិជ្ជកម្ម ១២
ការឆ្លើយតបផ្នែកនយោបាយ ១៣
៥. វិធីសាស្ត្រ និងទីតាំងផ្សារ ១៤
៦. ឧបសម្ព័ន្ធទី១
បម្រែបម្រួលថ្លៃលក់រាយ ១៥
៧. ឧបសម្ព័ន្ធទី២
បម្រែបម្រួលថ្លៃលក់ដុំ ១៦
៨. ឧបសម្ព័ន្ធទី៣
តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៧

# ទិដ្ឋភាពទូទៅ

កំណើនសេដ្ឋកិច្ច

| ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|
| ៥,៦% | ៥,៨% (ព្យាករណ៍) | ៦,១% (ព្យាករណ៍) |

*ធនាគារពិភពលោកបានកែសម្រួលការព្យាករពីកំណើនសេដ្ឋកិច្ចកម្ពុជាទៅ ៥,៨% ក្នុងឆ្នាំ ២០២៤ និង ៦,១% ក្នុងឆ្នាំ២០២៥។ ក្នុងខែមិថុនា ឆ្នាំ២០២៤ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ រួម (CPI) និងសន្ទស្សន៍តម្លៃស្បៀងអាហារ (FPI) នៅរាជធានីភ្នំពេញ មានស្ថេរភាពបើធៀបនឹង ខែមុន ប៉ុន្តែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុនបន្តិច។ គួរកត់សម្គាល់ថា គ្រួសារកម្ពុជាចំណាយ លើស្បៀងអាហារច្រើនគួរសម គឺ៥២% នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ។ គ្រួសារ ក្នុងក្រុមចំណាយទាបបំផុតបានចំណាយរហូតដល់៥៨% (CSES ២០២១)។*

អតិផរណា




*តម្លៃប្រេងឥន្ធនៈ (ទាំងប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូត) នៅកម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០២៤ បានថយចុះបន្តិចបើធៀបនឹងខែមុន ប៉ុន្តែវានៅតែមានតម្លៃខ្ពស់ជាងខែមិថុនា ឆ្នាំ២០២៣។*

ប្រេងឥន្ធនៈ




# របកគំហើញសំខាន់ៗ

**នៅខែមិថុនា ឆ្នាំ២០២៤ តម្លៃប៉ាន់ស្មាននៃកញ្ចប់ស្បៀងមូលដ្ឋានរបស់ WFP (BFB) មានចំនួន ១១៤.៦០០ រៀលក្នុងមនុស្សម្នាក់ក្នុងមួយខែ ស្មើនឹង ២៧,៩ ដុល្លារ គឺស្ទើរតែមិនប្រែប្រួលធៀបនឹងខែឧសភា ឆ្នាំ២០២៤។** គួរកត់សម្គាល់ថា ការចំណាយនៅតំបន់ជនបទបានកើនឡើងខ្លាំង។ និន្នាការនៃការកើនឡើងនៅផ្សារជនបទនេះ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គ្រួសារក្រីក្រដែលរស់នៅក្នុងតំបន់ទាំងនេះ ដោយសារបច្ចុប្បន្នពួកគេប្រឈមមុខនឹងការចំណាយលើការរស់នៅស្រដៀងគ្នាទៅនឹងអ្នក ដែលរស់នៅក្នុងតំបន់ទីប្រជុំជនដែរ ទោះបីជាពួកគាត់មានប្រាក់ចំណូលទាបជាង និងលទ្ធភាពទទួលបានឱកាសសេដ្ឋកិច្ចតិចជាងក៏ដោយ។ ធៀបតម្លៃទៅនឹងខែមិថុនា ឆ្នាំ២០២៣ (YoY) ការចំណាយប៉ាន់ស្មានបានកើនឡើង ៤,៦%។ ផ្សារតំបន់ជនបទបានកើនឡើងខ្ពស់គឺ ៧,៥% YoY បើធៀបទៅនឹងផ្សារនៅទីប្រជុំជន ដែលបានកើនតែ ៣,៣% YoY ។

**ផ្សារដែលបានតាមដាននៅតែមានដំណើរការល្អក្នុងខែមិថុនា ឆ្នាំ២០២៤។** អតិថិជនមកផ្សារនៅតែមានចំនួនតិច អាចដោយសារតែមានកំណើនតូបលក់ស្បៀងអាហារតូចៗច្រើន។

**ប្រទេសកម្ពុជាទទួលបានទឹកភ្លៀងទាបជាងធម្មតាបន្តិច ប៉ុន្តែស្ថានភាពរុក្ខជាតិមានកម្រិតដូចគ្នាទៅនឹងមធ្យមភាគច្រើនឆ្នាំ ក្នុងខែមិថុនា ឆ្នាំ២០២៤។** ការដាំដុះស្រូវវស្សាសម្រេចបាន ៨០% នៃផែនការប្រចាំឆ្នាំ។ ការព្យាករ El Niño, La Niña និង Southern Oscillation (ENSO) បានបង្ហាញថា លក្ខខណ្ឌអព្យាក្រឹតនៅតែបន្តមុននឹងបន្តគ្របដណ្តប់ដោយបាតុភូតឡានីញ៉ាពីខែសីហា ឆ្នាំ២០២៤ រហូតដល់ដើមឆ្នាំ២០២៥។ ស្ថិតក្នុងស្ថានភាពបែបនេះ **កម្ពុជារំពឹងថានឹងទទួលបានទឹកភ្លៀងចន្លោះពីធម្មតាទៅខ្ពស់ជាងធម្មតាបន្តិច ប៉ុន្តែនឹងមានសីតុណ្ហភាពខ្ពស់ជាងធម្មតាពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៤។**

# ការដំណើរការរបស់ផ្សារ

ក្នុងខែមិថុនា ឆ្នាំ២០២៤ សន្ទស្សន៍ដំណើរការរបស់ផ្សារ* (MFI) បានថយចុះបន្តិចបើធៀបនឹងខែមុន ប៉ុន្តែវានៅតែមានកម្រិតខ្ពស់។ ការថយចុះនេះដោយសារតែតម្លៃទំនិញសំខាន់ៗមិនអាចព្យាករបាន។ មិនមានការរាយការណ៍ពីការកើនឡើងនៃតម្លៃផ្គត់ផ្គង់ស្បៀងអាហារសំខាន់ៗក្នុងខែមិថុនា ឆ្នាំ២០២៤នេះទេ។




** សន្ទស្សន៍ដំណើរការផ្សារ (MFI) វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ សមាសធាតុនីមួយៗនៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់ បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សាររួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។ ចាប់ពីខែមេសា ឆ្នាំ២០២៣មក ការគណនា MFI និងសមាសធាតុសំខាន់ៗត្រូវបានកែសម្រួលដើម្បីបង្ហាញព័ត៌មានកាន់តែសុក្រិត។*

# ការទៅផ្សារ៖ ទិន្នាការអតិថិជន

នៅក្នុងខែមិថុនា ឆ្នាំ២០២៤ ចំនួនអតិថិជនទៅផ្សារបានថយចុះបង្គួរបើធៀបនឹងខែមុន ហើយវានៅតែមានចំនួនតិច។ នេះអាចដោយសារតែការកើនឡើងនៃតូបលក់ស្បៀងអាហារ តូចៗនៅតាមភូមិ ដែលបានកាត់បន្ថយតម្រូវការរបស់ប្រជាជនក្នុងការធ្វើដំណើរទៅកាន់ផ្សារធំដើម្បីទិញស្បៀងអាហារ។




**បម្រែបម្រួលនៃចំនួនអតិថិជន*មកផ្សារ**

** ប្រធានផ្សារ និងអ្នកលក់តាមបណ្ដា**ផ្សារចំនួន ៥៨ កន្លែង ដែលបានតាមដានតម្លៃ**នៅទូទាំងប្រទេស ក៏ត្រូវបានសម្ភាសន៍ស្ដីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សារនៅសប្ដាហ៍ទី៣នៃខែនេះ ធៀបនឹងសប្ដាហ៍ទី៣នៃខែមុន។ តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# **ថ្នាក់ជាតិ៖** តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ក្នុងខែមិថុនា ឆ្នាំ២០២៤ កញ្ចប់ស្បៀងអាហារមូលដ្ឋាន[1] (BFB) របស់ WFP ដែលបានប៉ាន់ស្មានមានតម្លៃជាមធ្យម **១១៤.៦០០ រៀល/ម្នាក់/ខែ** ប្រហែល ២៧,៩ ដុល្លារ ស្ទើរតែមិនមានការប្រែប្រួលបើធៀបនឹងខែឧសភា ឆ្នាំ២០២៤។ មិនមានគម្លាតនៃការចំណាយសម្រាប់ការរស់នៅរវាងតំបន់ជនបទ និងតំបន់ទីប្រជុំជនទៀតទេ ដោយសារការចំណាយនៅតំបន់ជនបទបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីខែមេសា ឆ្នាំ២០២៤មក ដោយសារតែធាតុអាកាសក្តៅ និងស្ងួតជាងធម្មតា បង្កឡើងដោយបាតុភូតអែលនីញ៉ូ។ និន្នាការនេះប៉ះពាល់ដល់គ្រួសារក្រីក្រដែលរស់នៅក្នុងតំបន់ជនបទ ព្រោះជាទូទៅ ពួកគាត់មានប្រាក់ចំណូលទាបជាង និងលទ្ធភាពទទួលបានឱកាសសេដ្ឋកិច្ចតិចជាង។

ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY) តម្លៃកញ្ចប់របស់ WFP ជាមធ្យម បានកើនឡើង ៤,៦%។ ផ្សារតំបន់ជនបទមានកំណើន ៧,៥% YoY គឺខ្ពស់ជាងតម្លៃកញ្ចប់នៅផ្សារតំបន់ទីប្រជុំជន[2] ដែលមានកំណើនតែ ៣,៣% YoY ប៉ុណ្ណោះ។




[1] *តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។*

[2] *ផ្សារនៅទីប្រជុំជនសំដៅដល់ផ្សារដែលស្ថិតនៅទីរួមខេត្ត ហើយផ្សារដទៃទៀតចាត់ទុកថាជាផ្សារនៅជនបទ។*

## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# **ថ្នាក់ជាតិ៖** និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែមិថុនា ឆ្នាំ២០២៤ តម្លៃលក់រាយអង្ករចម្រុះ ស៊ុតទា និងត្រកួន មាននិន្នាការចម្រុះ។ តម្លៃអង្ករចម្រុះបានកើនឡើងទាំងធៀបនឹងខែមុន (MoM) និងធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ដោយកើនឡើងខ្ពស់ YoY គឺ ២៤,៨%។ តម្លៃត្រកួនបានថយចុះបន្តិច MoM ប៉ុន្តែបានកើនឡើងគួរឱ្យកត់សម្គាល់ (១០,៥%) YoY។ ផ្ទុយមកវិញ តម្លៃលក់រាយស៊ុតទា បានកើនឡើងគួរឱ្យកត់សម្គាល់ (១០,៩%) MoM បើទោះជាវានៅតែមានតម្លៃទាប YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖*

*- ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។*

*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ។*

*- តម្លៃស្បៀងអាហារក្នុងខែមេសា ឆ្នាំ២០២៤ ត្រូវបានប្រមូលនៅក្នុងសប្តាហ៍ទី៤ ដែលខុសពីផែនការដែលត្រូវធ្វើនៅសប្តាហ៍ទី៣ ដោយសារតែការប្រារព្ធពិធីចូលឆ្នាំខ្មែរ។*

*- តម្លៃស៊ុតទា គិតជារៀលក្នុង១០គ្រាប់*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូកបីជាន់ និងប្រេងឆា

ក្នុងខែមិថុនា ឆ្នាំ២០២៤ តម្លៃលក់រាយប្រេងឆា សាច់ជ្រូកបីជាន់ និងត្រីផ្ទក់មាននិន្នាការប្រហាក់ប្រហែលគ្នា។ តម្លៃលក់រាយប្រេងឆា និងត្រីផ្ទក់ បានថយចុះទាំងធៀបនឹងខែមុន (MoM) ក៏ដូចជាធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY)។ តម្លៃលក់រាយសាច់ជ្រូកបីជាន់បានថយចុះបន្តិច MoM ប៉ុន្តែមិនមានការប្រែប្រួល YoY នោះទេ។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖*

*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ។*

*- តម្លៃស្បៀងអាហារក្នុងខែមេសា ឆ្នាំ២០២៤ ត្រូវបានប្រមូលនៅក្នុងសប្តាហ៍ទី៤ ដែលខុសពីផែនការដែលត្រូវធ្វើនៅសប្តាហ៍ទី៣ ដោយសារតែការប្រារព្ធពិធីចូលឆ្នាំខ្មែរ។*

*- តម្លៃប្រេងឆា គិតជា រៀលក្នុង៥លីត្រ*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

ក្នុងខែមិថុនា ឆ្នាំ២០២៤ តម្លៃមធ្យមលក់រាយស្បៀងអាហារដែលបានតាមដានភាគច្រើន (ក្រាហ្វិកខាងក្រោមឆ្វេង) មានទិសដៅប្រែប្រួលដូចគ្នា ទាំងនៅផ្សារជនបទ និងផ្សារទីប្រជុំជន ដោយបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នូវតម្លៃត្រីកូន និងស៊ុតទានៅតំបន់ជនបទ។ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់ WFP ក្នុងខែមិថុនា ឆ្នាំ២០២៤ មានការប្រែប្រួលតាមបណ្តាខេត្ត (ផែនទីខាងក្រោមស្តាំ) ដោយនៅផ្សារស្ទឹងត្រែង ក្នុងខេត្តស្ទឹងត្រែង (៣១,៣ ដុល្លារ) មានតម្លៃខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ១២% ខណៈនៅផ្សារសួង ក្នុងខេត្តត្បូងឃ្មុំ (២៥,៥ ដុល្លារ) មានតម្លៃទាបជាងតម្លៃមធ្យមថ្នាក់ជាតិ ៩%។ តម្លៃកញ្ចប់ស្បៀងអាហារដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិភាគច្រើនមាននៅផ្សារនៅទីប្រជុំជន។

**បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ**
**ខែឧសភា ឆ្នាំ២០២៤ និង ខែមិថុនា ឆ្នាំ២០២៤**




*សម្គាល់៖*
*- ទិន្នន័យតម្លៃពីផ្សារចំនួន៥៨។ មើលវិធីសាស្ត្រសម្រាប់ពត៌មានលម្អិត។*
*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ។*

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹង**
**តម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែមិថុនា ឆ្នាំ២០២៤)**



| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ៣៣% | ៦៧% |
| ៥% ទៅ ១០% ខ្ពស់ជាង | ៦៧% | ៣៣% |
| < ៥% ខ្ពស់ជាង | ៣៥% | ៦៥% |
| < ៥% ទាបជាង | ៤៥% | ៥៥% |
| ៥% ទៅ ១០% ទាបជាង | ៧១% | ២៩% |
| ≥ ១០% ទាបជាង | ០% | ០% |

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

ក្នុងខែមិថុនា ឆ្នាំ២០២៤ កម្ពុជាទទួលបានបរិមាណទឹកភ្លៀងចំនួន ២២០មីលីម៉ែត្រ ដែលមានកម្រិតទាបជាងបរិមាណទឹកភ្លៀងមធ្យមរយៈពេលវែង ដែលមានចំនួន ២៦០មីលីម៉ែត្រ។ បណ្តាខេត្តភាគច្រើននៅប្រទេសកម្ពុជាទទួលបានទឹកភ្លៀង[1] សរុបទាបជាងមធ្យមភាគច្រើនឆ្នាំបន្តិច លើកលែងតែបណ្តាខេត្តនៅតំបន់ឆ្នេរ និងភាគខាងត្បូងតំបន់ទំនាប។ ស្ថានភាពរុក្ខជាតិនៅទូទាំងប្រទេស ដូចបានបង្ហាញតាមរយៈសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)[2] មានកម្រិតដូចគ្នានឹងមធ្យមភាគច្រើនឆ្នាំ (សូមមើលក្រាហ្វិក និងផែនទីខាងក្រោម)។

ការព្យាករ El Niño, La Niña និង Southern Oscillation (ENSO) បានបង្ហាញថា លក្ខខណ្ឌអព្យាក្រឹតនៅតែបន្ត ហើយបាតុភូតឡានីញ៉ាំនឹងចាប់ផ្តើមពីខែសីហារហូតដល់ដើមឆ្នាំ២០២៥។ ស្ថិតក្រោមលក្ខខណ្ឌទាំងនេះ ប្រទេសកម្ពុជាទំនងជាទទួលបានទឹកភ្លៀងក្នុងកម្រិតធម្មតា ទៅខ្ពស់ជាងធម្មតាបន្តិច ប៉ុន្តែនឹងមានសីតុណ្ហភាពខ្ពស់ជាងធម្មតាពីខែកក្កដាដល់ខែកញ្ញា ឆ្នាំ២០២៤ ផ្អែកតាមការព្យាករតាមរដូវកាលរបស់ International Research Institute (IRI) of Columbia University និង European Centre for Medium-Range Weather Forecasts (ECMWF)។

## បរិមាណទឹកភ្លៀង និងសន្ទស្សន៍ NDVI មធ្យមថ្នាក់ជាតិ (ខែមិថុនា ឆ្នាំ២០២៤) និងប្រតិទិនដាំដុះតាមរដូវកាល




## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែមិថុនា ឆ្នាំ២០២៤




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

*[1] កម្ពស់ទឹកភ្លៀងជាមធ្យមសរុបសម្រាប់ខែមួយគឺជាផលបូកនៃកម្ពស់ទឹកភ្លៀងក្នុងរយៈពេល ៣ដេកាត (រៀងរាល់១០ថ្ងៃ) ក្នុងខែនោះ។*

*[2] សន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI) គឺជាសូចនាករជាតួលេខដែលត្រូវប្រើដើម្បីវាយតម្លៃសុខភាព និងដង់ស៊ីតេរុក្ខជាតិ ដោយវិភាគតម្លៃពន្លឺចាំងផ្លាតពីផែនដីតាមរយៈផ្កាយរណប។ វាផ្តល់នូវតម្លៃចាប់ពីលេខ 0 ដល់ ១ ដែលតម្លៃខ្ពស់បង្ហាញថារុក្ខជាតិកាន់តែមានសុខភាពល្អ។*

# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

ក្នុងខែមិថុនា ឆ្នាំ២០២៤ ស្ថានភាពរុក្ខជាតិជារួមមានកម្រិតស្របគ្នានឹងរបាយទឹកភ្លៀងដែរ។ ស្ថានភាពរុក្ខជាតិនៅក្នុងតំបន់ដាំដុះដំណាំភាគច្រើន នៅភាគខាងត្បូង និងភាគអាគ្នេយ៍នៃប្រទេសកម្ពុជាមានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។ ផ្ទុយមកវិញ ស្ថានភាពរុក្ខជាតិនៅបណ្តាខេត្តភាគពាយ័ព្យមានកម្រិតទាបជាងមធ្យមភាគច្រើនឆ្នាំ (ផែនទីខាងស្តាំ)។

ការដាំដុះស្រូវរដូវវស្សា ក្នុងខែមិថុនា ឆ្នាំ២០២៤ សម្រេចបានប្រមាណ ៥០% នៃផែនការសរុបថ្នាក់ជាតិ ស្មើនឹងចំនួន ១,០៦ លានហិកតា។ ល្បឿននៃការបង្កបង្កើនផលនេះយឺតជាងកាលពីឆ្នាំមុន ដោយសារតែភ្លៀងធ្លាក់យឺតយ៉ាវ។

**ភាពមិនប្រក្រតីនៃ NDVI ក្នុងខែមិថុនា ឆ្នាំ២០២៤**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*

# ពាណិជ្ជកម្ម

ក្នុងឆមាសទី១នៃឆ្នាំ២០២៤ ការនាំចេញផ្លូវការសរុប (មិនរាប់បញ្ចូលមាសមិនមែនរូបិយវត្ថុ) របស់កម្ពុជា បន្តនិន្នាការកើនឡើង ជាមួយនឹងការកើនឡើងគួរឱ្យកត់សម្គាល់ គឺ ១២,៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានតម្លៃ ១២,៣ ពាន់លានដុល្លារ។ គោលដៅនាំចេញសំខាន់ៗ រួមមាន សហរដ្ឋអាមេរិក វៀតណាម ចិន កាណាដា និងអេស្ប៉ាញ។ គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ ការនាំចេញទំនិញជាស្បៀងអាហារចំនួន ១,១៨៦ លានដុល្លារ (ក្រាហ្វិកខាងស្តាំ) ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៩៣៦ លានដុល្លារ (+១៧% YoY) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុង ដែលអាចបរិភោគបាន បន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ២៥០ លានដុល្លារ (+២ YoY)។ ការនាំចេញអង្ករមានចំនួនសរុប ៣៣៨.៦៥៤ តោន (មានតម្លៃស្មើ ២៩៧ លានដុល្លារ) ក្នុងឆមាសដំបូងនៃឆ្នាំ២០២៤។ ចំនួននេះបានកើនឡើង ២,៧% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ បន្ថែមលើនេះ ការនាំចេញស្រូវមានចំនួនជាង ២,៥២ លានតោន មានតម្លៃស្មើនឹង ៧២៧ លានដុល្លារ ត្រូវបាននាំចេញក្នុងរយៈពេលដូចគ្នា។

ក្នុងឆមាសទី១នៃឆ្នាំ២០២៤ ការនាំចូលជាផ្លូវការសរុប (មិនរាប់បញ្ចូលមាសមិនមែនរូបិយវត្ថុ) របស់កម្ពុជាដោយកើនឡើងគួរឱ្យកត់សម្គាល់ គឺ ១២,៨% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានតម្លៃ ១៣,៨ ពាន់លានដុល្លារ។ ការនាំចូលមានប្រភពមកពីប្រទេសចិន វៀតណាម ថៃ សាំងហ្គាពួរ និងឥណ្ឌូនេស៊ី។ ក្នុងចំនោមការនាំចូលសរុប មានទំនិញជាស្បៀងអាហារចំនួន ៦៨១ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៤២លានដុល្លារ (+២០% YoY) និងអាហារដទៃទៀតចំនួន ៦៣៩ លានដុល្លារ (+១១% YoY)។ ក្នុងរយៈពេលដូចគ្នា ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ១៦៧ លានដុល្លារ (+១៥% YoY) ភាគច្រើនមកពីប្រទេសវៀតណាម ថៃ និងចិន និងប្រេងឥន្ធនៈមានតម្លៃ ២.០៤២ លានដុល្លារ (+១៨% YoY)។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជា លានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ត្រឹមខែមិថុនា ឆ្នាំ២០២៤




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ចូលថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤*

# ការឆ្លើយតបផ្នែកនយោបាយ

FAO សន្យាអភិរក្សវិស័យជលផលដោយពង្រឹងការអនុវត្តនិងការកែទម្រង់ច្បាប់។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាផលិតត្រី និងសត្វក្នុងទឹកបានប្រមាណ ៥៥០.០០០ តោន ក្នុងមួយឆ្នាំ ដែលរួមចំណែកប្រហែល ១២% នៃផលិតផលក្នុងស្រុកសរុប (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤)។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានជំរុញឱ្យមន្ត្រីរបស់ខ្លួន សិក្សាពីប្រភេទពូជត្រីដែលមានសក្តានុពល និងជិតផុតពូជ សម្រាប់ហេតុផលបច្ចេកទេសផង និងលក្ខណៈសេដ្ឋកិច្ចផង ដើម្បីធានាបានប្រាក់ចំណេញ ប្រសិទ្ធភាព និងនិរន្តរភាពពិតប្រាកដ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤)។ គោលនយោបាយទាំងនេះអាចកាត់បន្ថយតម្លៃត្រីបានយ៉ាងមានសក្តានុពល តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ និងនិរន្តរភាពនៃស្តុកត្រី។

ក្រោមបទប្បញ្ញត្តិដែលបានអនុវត្តថ្មី រាជរដ្ឋាភិបាលកម្ពុជា (RGC) បានដាក់ចេញនូវការលើកទឹកចិត្តផ្នែកពន្ធផ្សេងៗ សម្រាប់សហគ្រាសធុនតូច និងមធ្យម (MSMEs) ដែលប្រតិបត្តិការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការលើកទឹកចិត្តទាំងនេះជំរុញឱ្យសហគ្រាសធុនតូច និងមធ្យម ចុះបញ្ជីអាជីវកម្មរបស់ពួកគេ ជាផ្លូវការជាមួយក្រសួងពាណិជ្ជកម្ម (MoC) និងអគ្គនាយកដ្ឋានពន្ធដារ (GDT) (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤)។

កាលពីខែមិថុនា ឆ្នាំ២០២៤ ក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ធនាគារពិភពលោក បានអនុម័តឥណទានចំនួន ២៧៥លានដុល្លារ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចរយៈពេលវែង និងភាពធន់ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤)។ ស្រដៀងគ្នាដែរ ADB បានប្តេជ្ញាផ្តល់ថវិកាប្រមាណ ១,២៦ ពាន់លានដុល្លារ ដើម្បីគាំទ្រដល់រដ្ឋាភិបាលកម្ពុជាពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដោយផ្តោតលើការធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍន៍មូលធនមនុស្ស និងភាពធន់នឹងអាកាសធាតុ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤)។ ទាំងនេះនឹងរួមចំណែកធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានស្ថិរភាព វិបុលភាព និងធន់ ត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងលើកកម្ពស់សុខុមាលភាពសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន។

បន្ទាប់ពីទទួលបានជោគជ័យនូវភូមិគំរូចំនួន ៣០ ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) កំពុងរៀបចំប្រមូលព័ត៌មានអំពីស្ថានភាពភូមិផ្សេងទៀត ដោយមានគោលដៅបង្កើតភូមិគំរូបន្ថែមចំនួន ២៥០ ទៀត នៅចុងអាណត្តិទី៧ ឆ្នាំ២០២៨។ គំនិតផ្តួចផ្តើមនេះមានគោលបំណងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់ប្រាក់កម្ចីដែលមានការប្រាក់ទាប ដើម្បីពង្រីកអាជីវកម្មខ្នាតតូចនៅក្នុងសហគមន៍មូលដ្ឋាន (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤)។

## ចំនួនប្រជាជនបានចាក់វ៉ាក់សាំងកូវីដ-១៩




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៤ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

ក្នុងខែមករា ឆ្នាំ២០២៤ WFP បានបន្ថែមផ្សារចំនួន ២ ទៀត (ឈ្មោះថា ផ្សារបត់រំដួល និងផ្សារភ្នំក្រវាញ) ដែលស្ថិតក្រោមការសាកល្បងលទ្ធកម្មថ្មីរបស់កម្មវិធី HGSFP ដែលមានទីតាំងនៅខេត្តពោធិ៍សាត់ ហើយបានប្រមូលទិន្នន័យតម្លៃទំនិញចំនួន ៧៨ មុខ ក្នុងនោះមានទំនិញជាស្បៀងអាហារបន្ថែមចំនួន ២៧ មុខ (សូមមើលឧបសម្ព័ន្ធទី ១ & ២)។ តម្លៃទំនិញជាស្បៀងអាហារដែលបានបន្ថែមចំនួន ២៧ មុខនេះក៏នឹងប្រមូលជាប្រចាំនៅក្នុងខេត្តដែលមានកម្មវិធី HGSFP ផ្សេងទៀតផងដែរ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| អង្ករចម្រុះ | Kg | 2,749 | → 1.7% | → 2.7% | ↑ 24.8% |
| អង្ករបាក់៣០-៣៥% | Kg | 2,813 | ↑ 6.7% | ↑ 7.7% | ● |
| ត្រីផ្ទក់(រស់) | Kg | 10,900 | → -0.4% | ↑ 5.1% | ↓ -10.6% |
| ត្រីប្រា(រស់) | Kg | 7,550 | → 3.1% | → 3.6% | ↑ 9.0% |
| ត្រីអណ្តែង(រស់) | Kg | 7,762 | → -2.6% | ↑ 9.0% | → -1.4% |
| ត្រីងៀត(ផ្ទក់) | Kg | 27,625 | → 0.8% | ↑ 6.5% | → 1.7% |
| ប្រហុក | Kg | 8,941 | → -4.5% | → -4.3% | ↓ -5.3% |
| ត្រីពោធិ៍ | Kg | 9,750 | ↓ -10.5% | ↓ -9.7% | ● |
| ត្រីខ្យា | Kg | 12,000 | ● | → 0.0% | ● |
| ត្រីសណ្តាយ | Kg | 30,000 | ● | ● | ● |
| សាច់ជ្រូកពាជាន់ | Kg | 16,469 | → -1.9% | ↑ 12.2% | → 0.0% |
| ឆ្អឹងជំនីជ្រូក | Kg | 16,379 | → -1.2% | ↑ 10.9% | ● |
| ឆ្អឹងជ្រូកស៊ុប | Kg | 13,505 | → 0.1% | ↑ 13.4% | ● |
| ជើងជ្រូក | Kg | 13,594 | → -0.7% | ↑ 15.4% | ● |
| សាច់គោយារ | Kg | 15,523 | → -0.5% | ↓ -6.1% | ↓ -9.2% |
| សាច់មាន់ (បីសាសន៍) | Kg | 12,167 | ↓ -13.7% | ↓ -21.9% | ↓ -10.3% |
| សាច់មាន់ (ស៊ីភី) | Kg | 13,077 | ↓ -8.5% | ↓ -11.9% | ● |
| ស៊ុតទា | 10 eggs | 6,018 | ↑ 10.9% | ↑ 22.4% | ↓ -6.4% |
| ស៊ុតទាប្រៃ | 10 eggs | 7,321 | → 3.3% | ↑ 6.0% | → -2.8% |
| ប្រេងឆា | 5 litres | 25,765 | → -0.4% | → 3.3% | ↓ -6.3% |
| អំបិលម៉ត់អ៊ីយ៉ូត | Kg | 1,329 | → -2.7% | → -2.2% | ↑ 7.1% |
| ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,486 | → 1.1% | → 0.6% | → 1.2% |
| សណ្តែកដី | Kg | 9,875 | → -0.6% | → -0.9% | → 0.1% |
| សណ្តែកសៀង | Kg | 5,472 | → -1.3% | → -2.1% | → 2.2% |
| សណ្តែកខៀវ | Kg | 5,863 | → -1.6% | → 0.1% | → -4.3% |
| ត្រកួន | Kg | 3,153 | → -1.0% | ↑ 11.0% | ↑ 10.5% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ការ៉ុត | Kg | 3,613 | ↑ 11.5% | ↑ 12.2% | ↑ 7.1% |
| ស្លឹកបាស | Kg | 4,718 | ↓ -10.1% | → -2.0% | → -0.9% |
| ស្លឹកម្រុំ | Kg | 5,794 | ↑ 14.3% | ↑ 15.9% | ↑ 15.1% |
| ស្ពៃក្រញាញ់ | Kg | 3,936 | ↓ -18.3% | → 1.4% | ↓ -7.6% |
| ស្ពៃតឿ | Kg | 3,784 | ↓ -24.0% | → 2.9% | ↓ -11.2% |
| ស្ពៃចង្កឹះ | Kg | 3,550 | ↓ -24.9% | → 2.9% | ↑ 5.0% |
| ស្ពៃខៀវ | Kg | 3,514 | ↓ -24.9% | → -1.3% | ↓ -11.7% |
| ផ្ទីដូង | Kg | 4,247 | ↓ -13.4% | ↑ 21.8% | ↑ 13.0% |
| ស្លឹកងប់ | Kg | 6,339 | ↓ -6.6% | ↑ 15.3% | ↑ 14.7% |
| ត្រួយល្ពៅ | Kg | 5,694 | → -3.5% | ↑ 6.7% | ↑ 12.4% |
| ផ្លែល្ពៅ | Kg | 3,319 | → 3.6% | ↑ 41.0% | ↑ 49.3% |
| ឃ្លោក | Kg | 3,111 | ↓ -6.9% | ↑ 27.6% | ↑ 38.3% |
| ត្រឡាច | Kg | 3,149 | ↓ -16.3% | ↑ 17.0% | ↑ 33.3% |
| ត្រប់វែង | Kg | 2,971 | ↓ -18.5% | ↑ 6.4% | → -1.1% |
| ត្រប់ស្រួយ | Kg | 3,115 | ↓ -37.5% | → 1.4% | ↑ 16.6% |
| ប៉េងប៉ោះ | Kg | 5,475 | ↓ -14.9% | ↑ 64.0% | ↑ 52.0% |
| ននោងមូល | Kg | 3,130 | ↓ -18.3% | → 3.2% | ↑ 5.8% |
| ននោងជ្រុង | Kg | 3,081 | ↓ -23.6% | → 1.3% | → -2.9% |
| ល្ហុងខ្ចី | Kg | 1,812 | → 3.8% | ↑ 22.0% | → -0.6% |
| សណ្តែកកួរ | Kg | 9,206 | ↓ -44.0% | ↑ 100.1% | ↑ 86.7% |
| ត្រយូងចេក | Kg | 3,683 | ↓ -8.7% | ↑ 50.8% | ↑ 56.5% |
| ផ្កាខាត់ណា | Kg | 6,986 | → -1.6% | ↑ 28.5% | → -2.2% |
| ដើមខាត់ណា | Kg | 5,594 | ↑ 13.0% | ↑ 20.4% | ↓ -9.0% |
| ដំឡូងផ្កាពណ៌លឿង* | Kg | 2,633 | ↓ -5.4% | ↑ 6.5% | → 1.9% |
| ខ្ទឹមសរ | Kg | 7,338 | ↓ -7.5% | → -4.4% | ↓ -5.4% |
| អំពិលទុំ (មានគ្រាប់) | Kg | 4,203 | → -0.8% | ↑ 7.0% | ↑ 5.8% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| អំពិលទុំ (អត់គ្រាប់) | Kg | 10,333 | ↓ -6.6% | ↑ 5.1% | ● |
| ព្រលឹត | Kg | 2,257 | ↓ -16.4% | ↓ -14.0% | ● |
| ត្រួយស្ពៃ | Kg | 10,056 | → -1.9% | ↓ -23.4% | ● |
| ត្រួយននោង | Kg | 5,000 | ↓ -13.0% | ● | ● |
| ត្រួយ ឬ ផ្កាអង្គារដី | Kg | 4,000 | ↓ -33.3% | ↓ -46.7% | ● |
| ផ្សិតអំបោះ | Kg | 9,655 | ↓ -7.4% | ↑ 10.0% | ● |
| ស្ពៃក្តោប | Kg | 3,085 | ↓ -18.6% | → 4.7% | ● |
| ស្ពៃបូកគោ | Kg | 3,286 | ↓ -21.4% | ↓ -16.9% | ● |
| សណ្តែកបណ្តុះ | Kg | 2,538 | ↓ -10.4% | ↓ -9.0% | ● |
| ក្តឹបឱឡឹក | Kg | 2,792 | ↓ -24.8% | → 4.7% | ● |
| ពោតបារាំង | Kg | 5,045 | ↓ -10.1% | → 3.2% | ● |
| ស្ពៀតពោត | Kg | 12,286 | ↑ 18.0% | ↑ 38.7% | ● |
| ផ្លែពោត | Kg | | ● | ● | ● |
| ផ្លែត្នោតខ្ចី(ចិតរួច) | Kgl | 4,300 | ↓ -23.4% | ↓ -35.5% | ● |
| ត្រសក់ | Kg | 2,987 | ↓ -7.0% | ↓ -16.1% | ● |
| ម្ទេសត្រាវ | Kg | 4,574 | ↓ -14.2% | → 0.5% | ● |
| ម្ទេសផ្លៃថាវ | Kg | 2,789 | ↓ -19.2% | ↓ -9.2% | ● |
| ទំពាំង | Kg | 4,056 | ↓ -28.3% | → -4.6% | ● |
| ចេកណាំវ៉ាទុំ | Kg | 2,801 | ↑ 14.0% | ↑ 24.5% | ↑ 19.7% |
| ស្វាយកែវរមៀតទុំ | Kg | | ● | ● | ● |
| ម្នាស់ទុំ | Kg | 3,094 | → 1.7% | ↑ 10.0% | ● |
| ទឹកដោះគោស្រស់ | 140 ml | 1,962 | → -0.3% | → -1.9% | ↓ -7.1% |
| កូកាកូឡា | 330 ml | 1,982 | → 1.2% | → -0.9% | → -0.2% |
| សាំងធម្មតា | litre | 4,145 | → -3.6% | → -2.6% | → 1.2% |
| ម៉ាស៊ូត | litre | 3,887 | → -2.2% | ↓ -5.4% | → 2.5% |
| ជីអ៊ុយរ៉េ | Kg | 2,642 | → 3.4% | → -2.6% | ↓ -12.1% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឌ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖
- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ៖ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| អង្ករចម្រុះ | Kg | 2,573 | → 1.2% | → 2.0% | ↑ 25.7% |
| អង្ករបាក់៣០-៣៥% | Kg | 2,587 | → 3.7% | ↑ 5.3% | • |
| ត្រីផ្ទក់(រស់) | Kg | 9,779 | → -2.0% | ↑ 5.7% | ↓ -12.7% |
| ត្រីប្រា(រស់) | Kg | 6,674 | → 1.5% | → 2.0% | ↑ 10.1% |
| ត្រីអណ្តែង(រស់) | Kg | 7,136 | → -1.5% | ↑ 11.6% | → 3.5% |
| ត្រីងៀត(ផ្ទក់) | Kg | 25,667 | → 2.8% | ↑ 8.2% | → 0.8% |
| ប្រហុក | Kg | 7,853 | ↓ -6.3% | → -4.5% | → -5.0% |
| ត្រីពោធិ៍ | Kg | 8,714 | ↓ -10.1% | ↓ -8.5% | • |
| ត្រីខ្យា | Kg | 11,000 | • | ↑ 10.0% | • |
| ត្រីសណ្តាយ | Kg | 25,000 | • | • | • |
| សាច់ជ្រូកពជាន់ | Kg | 15,146 | → -2.2% | ↑ 13.4% | → 0.9% |
| ឆ្អឹងជំនីជ្រូក | Kg | 15,126 | → -2.2% | ↑ 13.0% | • |
| ឆ្អឹងជ្រូកស៊ុប | Kg | 12,487 | → -0.3% | ↑ 17.4% | • |
| ជើងជ្រូក | Kg | 12,482 | → -1.5% | ↑ 18.5% | • |
| សាច់គោឃាវ | Kg | 14,008 | → -0.9% | ↓ -6.0% | ↓ -9.0% |
| សាច់មាន់ (បីសាសន៍) | Kg | 11,250 | ↓ -13.5% | ↓ -23.2% | ↓ -8.4% |
| សាច់មាន់ (ស៊ីភី) | Kg | 12,423 | ↓ -7.2% | ↓ -8.2% | • |
| ស៊ុតទា | 10 eggs | 5,625 | ↑ 12.3% | ↑ 25.1% | ↓ -6.7% |
| ស៊ុតទាប្រៃ | 10 eggs | 6,821 | → 2.6% | ↑ 6.9% | → -2.7% |
| ប្រេងឆា | 5 litres | 24,804 | → -1.0% | → 3.8% | ↓ -5.9% |
| អំបិលម៉ត់អ៊ីយូត | Kg | 1,075 | ↓ -5.8% | → -2.0% | ↑ 9.9% |
| ទឹកត្រី (រូបបង្កងប៉ាក) | 730 ml | 3,152 | → 3.9% | → 3.0% | → 3.9% |
| សណ្តែកដី | Kg | 9,051 | → -0.3% | → -1.3% | → 0.9% |
| សណ្តែកសៀង | Kg | 4,733 | ↓ -8.7% | ↓ -5.9% | → 0.8% |
| សណ្តែកខៀវ | Kg | 5,388 | → -0.4% | → 0.2% | → -2.5% |
| ត្រកួន | Kg | 2,560 | → 1.8% | ↑ 10.7% | ↑ 16.6% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ការ៉ុត* | Kg | 3,073 | ↑ 16.1% | ↑ 16.3% | ↑ 12.2% |
| ស្លឹកបាស | Kg | 3,571 | ↓ -17.8% | ↓ -11.6% | → 0.3% |
| ស្លឹកម្រុំ | Kg | 4,333 | → -0.9% | ↑ 8.3% | ↑ 20.9% |
| ស្ពៃក្រញាញ់ | Kg | 3,284 | ↓ -20.2% | → -0.9% | ↓ -5.2% |
| ស្ពៃតឿ | Kg | 3,077 | ↓ -27.4% | → -3.4% | ↓ -11.4% |
| ស្ពៃចង្កឹះ | Kg | 2,889 | ↓ -27.5% | → -2.7% | ↑ 8.8% |
| ស្ពៃខៀវ | Kg | 2,827 | ↓ -29.0% | → -3.0% | ↓ -9.4% |
| ផ្ទីដូង | Kg | 3,316 | ↓ -15.6% | ↑ 18.1% | ↑ 16.2% |
| ស្លឹកងប់ | Kg | 5,609 | ↑ 5.1% | ↑ 28.2% | ↑ 31.3% |
| ត្រយូយល្ពៅ | Kg | 4,538 | → -3.2% | ↓ -6.1% | ↑ 14.8% |
| ផ្លែល្ពៅ | Kg | 2,715 | ↑ 6.2% | ↑ 44.4% | ↑ 55.8% |
| ឃ្លោក | Kg | 2,500 | ↓ -5.7% | ↑ 36.1% | ↑ 42.9% |
| ត្រឡាច | Kg | 2,589 | ↓ -18.7% | ↑ 19.2% | ↑ 40.4% |
| ត្រប់វែង | Kg | 2,397 | ↓ -21.7% | → 4.5% | → 1.4% |
| ត្រប់ស្រួយ | Kg | 2,373 | ↓ -45.8% | ↓ -9.1% | ↑ 14.6% |
| ប៉េងប៉ោះ | Kg | 4,756 | ↓ -18.4% | ↑ 78.3% | ↑ 62.4% |
| ននោងមូល | Kg | 2,619 | ↓ -16.5% | ↑ 5.5% | ↑ 11.3% |
| ននោងជ្រុង | Kg | 2,643 | ↓ -20.7% | ↑ 8.4% | ↑ 6.5% |
| ល្ហុងខ្ចី | Kg | 1,442 | → 0.7% | ↑ 26.2% | ↑ 8.3% |
| សណ្តែកកួរ | Kg | 7,358 | ↓ -49.3% | ↑ 81.4% | ↑ 78.5% |
| ត្រយូងចេក | Kg | 3,092 | ↓ -7.2% | ↑ 49.2% | ↑ 68.1% |
| ផ្កាខាត់ណា | Kg | 6,169 | → -2.7% | ↑ 31.5% | → -1.1% |
| ដើមខាត់ណា | Kg | 4,719 | ↑ 14.1% | ↑ 19.0% | ↓ -11.8% |
| ដំឡូងផ្កាពណ៌លឿង* | Kg | 2,207 | → -0.9% | ↑ 8.8% | → 4.2% |
| ខ្ទឹមសរ | Kg | 6,770 | ↓ -8.7% | → -4.7% | → -4.9% |
| អំពិលទុំ (មានគ្រាប់) | Kg | 3,741 | → -0.8% | ↑ 8.0% | ↑ 12.4% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| អំពិលទុំ (អត់គ្រាប់) | Kg | 9,000 | → -4.6% | → 1.6% | • |
| ព្រលឹត | Kg | 1,707 | ↓ -24.5% | ↓ -14.3% | • |
| ត្រួយស្អំ | Kg | 8,278 | → 0.3% | ↓ -25.2% | • |
| ត្រួយននោង | Kg | 5,000 | ↑ 25.0% | • | • |
| ត្រួយ ឬ ផ្កាអង្គារដី | Kg | 3,000 | ↓ -34.2% | ↓ -45.5% | • |
| ផ្សិតអំបោះ | Kg | 7,952 | ↓ -8.1% | ↑ 7.8% | • |
| ស្ពៃក្តោប | Kg | 2,527 | ↓ -21.3% | ↑ 9.1% | • |
| ស្ពៃបូកគោ | Kg | 2,668 | ↓ -21.4% | ↓ -15.1% | • |
| សណ្តែកបណ្តុះ | Kg | 2,032 | ↓ -11.3% | ↓ -11.0% | • |
| ក្តឹបឱឡឹក | Kg | 2,125 | ↓ -29.2% | ↑ 6.3% | • |
| ពោតបារាំង | Kg | 4,273 | ↓ -7.2% | ↑ 10.7% | • |
| ស្ងៀតពោត | Kg | 9,964 | ↑ 11.3% | ↑ 43.8% | • |
| ផ្លែពោត | Kg | | • | • | • |
| ផ្លែត្នោតខ្ចី(ចិតរួច) | Kgl | 3,800 | ↓ -26.3% | ↓ -36.7% | • |
| ត្រសក់ | Kg | 2,451 | → -3.5% | ↓ -18.4% | • |
| ម្ទេសត្រាវ | Kg | 3,785 | ↓ -14.3% | → -0.7% | • |
| ម្ទេសផ្លៃថាវ | Kg | 2,341 | ↓ -16.4% | → -4.7% | • |
| ទំពាំង | Kg | 3,067 | ↓ -33.9% | ↓ -15.4% | • |
| ចេកណាំវ៉ាទុំ | Kg | 2,413 | ↑ 20.0% | ↑ 32.4% | ↑ 30.6% |
| ស្វាយកែវរមៀតទុំ | Kg | | • | • | • |
| ម្នាស់ទុំ | Kg | 2,663 | → 2.1% | ↑ 9.8% | • |
| ទឹកដោះគោស្រស់ | 140 ml | 1,621 | → -1.3% | ↓ -5.0% | ↓ -9.1% |
| កូកាកូឡា | 330 ml | 1,585 | → -1.5% | → -1.5% | → 4.7% |
| សាំងធម្មតា | litre | 4,004 | → -4.5% | → -1.7% | → 2.2% |
| ម៉ាស៊ូត | litre | 3,754 | → -3.7% | ↓ -5.3% | → 1.6% |
| ជីអ៊ុយរ៉េ | Kg | 2,110 | → -2.7% | ↓ -7.7% | ↓ -12.3% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឱ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.7 | 34,537 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.9 | 30,180 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 16.5 | 20,390 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 9.6 | 3,469 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 5.7 | 2,210 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.2 | 22,227 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.6 | 1,570 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **114,600** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឱ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើយ។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ និងការតាមដានតាមរដូវកាល ខែមិថុនា ឆ្នាំ២០២៤ WFP ប្រចាំប្រទេសកម្ពុជា។*